ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ធំ

- សាលក្រមលេខ: ៦៤ "ឝ"
ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២៣
- សំណុំរឿងព្រហ្មទណ្ឌលេខ:៣៧៦
ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣
- សំណុំរឿងស៊ើបសួរលេខ:១៧៣
ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣
- សំណុំរឿងជំនុំជម្រះលេខ:៣១៤
ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃទី 05 ខែ...... ឆ្នាំ២០២៣
ក្រឡាបញ្ជី

[redacted]

# គាននាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកំពង់ធំ

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តកំពង់ធំ នាថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង០២ និង០០នាទីរសៀល ដែលមានសមាសភាពដូចខាងក្រោម៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ធំ ជាប្រធានក្រុមប្រឹក្សា

លោក [redacted]នុប្រធានសាលាដំបូងខេត្តកំពង់ធំ ជាចៅក្រមប្រឹក្សា

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តកំពងធំ ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពង់ធំ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ធំ

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ:៣៧៦ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣ ដែលមាន៖

**<u>ជនជាប់ចោទ៖</u>**

១.ឈ្មោះ [redacted] ចាន់ផន ភេទប្រុស អាយុ១៦ឆ្នាំ កើតឆ្នាំ២០០៧ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ កម្រិតវប្បធម៌៖រៀនថ្នាក់ទី០៦ថ្មី ទីកន្លែងកំណើតនៅ [redacted] ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកំពង់ធំ។ ឪពុកឈ្មោះ [redacted] ចន្ថា "រ" ម្តាយឈ្មោះ [redacted] សារី "រ" នៅលីវ។ ទោសពីមុនគ្មាន។

-បានចូលមកបង្ហាញខ្លួននៅចំពោះមុខនគរបាលយុត្តិធម៌ តំណាងអយ្យការ និងចៅក្រមស៊ើបសួរ។

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៖១៨៧/២០២៣ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ធំ។



Scanned with CamScanner

២.ឈ្មោះ [redacted] ម៉ៅ ភេទប្រុស កើតឆ្នាំ២០០៥ អាយុ១៨ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ កម្រិតវប្បធម៌៖រៀនថ្នាក់ទី៤ ទីកន្លែងកំណើតនៅ [redacted] ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្ននៅភូមិលាវ ឃុំក្រវ៉ា ស្រុកបារាយណ៍ ខេត្តកំពង់ធំ។ ឪពុកឈ្មោះ ផល "ស" ម្ដាយឈ្មោះ [redacted] ផៃ "រ" នៅលីវ។ ទោសពីមុនគ្មាន។

-បានចូលមកបង្ហាញខ្លួននៅចំពោះមុខនគរបាលយុត្តិធម៌ តំណាងអយ្យការ និងចៅក្រមស៊ើបសួរ។

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ៖១៨៦/២០២៣ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ធំ។

៣.ឈ្មោះ [redacted] សុភាក់ ភេទប្រុស កើតឆ្នាំ១៩៩៥ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅ [redacted] ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកំពង់ធំ ឪពុកឈ្មោះ [redacted] បឿន "រ" ម្ដាយឈ្មោះ [redacted] លី "រ" ពោះម៉ាយ មានកូន០២នាក់ ។

-មិនបានចូលមកបង្ហាញខ្លួននៅគ្រប់ដំណាក់កាលនីតិវិធីតុលាការ។

-ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ៖៧០ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ធំ។

ត្រូវបានជាប់ចោទពីបទ: **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារប្រើអាវុធ** ប្រព្រឹត្តនៅលើផ្លូវបេតុងខាងលិចរបងវត្តព្រៃលាប ស្ថិតនៅភូមិរលាប ឃុំក្រវ៉ា ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣ តាមមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ។

**មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ ចាន់ ឡាយភាគ**

មេធាវី [redacted] មានការិយាល័យក្រុមមេធាវី អាស៊ីកម្ពុជា នៅវីឡាលេខ៦៤ ផ្លូវលេខ៥៩២ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

**ដើមបណ្ដឹងរដ្ឋប្បវេណី**

ឈ្មោះ [redacted] ឡេក ភេទប្រុស អាយុ ៤១ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅ [redacted] ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្ននៅភូ [redacted] ខេត្តកំពង់ធំ។ ឪពុកឈ្មោះ [redacted] ឡេក "ស" ម្ដាយឈ្មោះ [redacted] លាវ "រ" ប្រពន្ធឈ្មោះ [redacted] រី "រ" មានកូន០១នាក់។

**១. អង្គហេតុដែលប្ដឹងមកតុលាការមានដូចតទៅ**

យោងតាមដីកាសន្និដ្ឋានស្ថាពរ និងដីកាដំណោះស្រាយបញ្ជូនសំណុំរឿងទៅជំនុំជម្រះ បញ្ជាក់ថា៖ កាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣ នៅចំណុចផ្លូវបេតុងខាងលិច ជាប់របងវត្តព្រៃរលាប ភូមិរលាប ឃុំក្រវ៉ា ស្រុកបារាយណ៍ ខេត្តកំពង់ធំ មានករណី **ហិង្សាដោយចេតនាមានអាវុធ** (ដុំថ្ម) មួយបានកើតឡើង បង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ចាន់ថន, ជនជាប់ចោទឈ្មោះ [redacted] ម៉ៅ, ជនជាប់ចោទឈ្មោះ [redacted] សុភាក់ បានធ្វើសកម្មភាពយកដុំថ្មគប់ទៅលើជនរងគ្រោះឈ្មោះ [redacted] គីមហ៊ង ភេទប្រុស អាយុ ១៧ឆ្នាំ បណ្ដាលឱ្យរងរបួសចំភ្នែកជាទម្ងន់។ ក្រោយកើតហេតុ ជនរងគ្រោះបានដាក់ពាក្យបណ្ដឹងមកសមត្ថកិច្ចឱ្យជួយអន្តរាគមន៍។

- **បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ៖៣១១/២០២៣ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ធំ។

-**បានឃើញ** ដីកាដំណោះស្រាយបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ៖២៥០០/២០២៣ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ធំ។

-**បានឃើញ** ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខ៖៤០៨ ត.ព្រ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តកំពង់ធំ។



Scanned with CamScanner

## ២. ពេលសវនាការ

- ជនជាប់ចោទឈ្មោះ [redacted] ចាន់ថន បានឆ្លើយបញ្ជាក់ថា៖ នៅថ្ងៃកើតហេតុ ខ្លួនមិនបានគប់គេនោះទេ។ ឈ្មោះ ម៉ៅ ឈ្មោះ ភាក់ ឈ្មោះ បូរ និងម្នាក់ទៀតមិនស្គាល់ ជាអ្នកគប់ដុំថ្មដាក់គេ។ មូលហេតុដែលពួកវាគប់នោះ ដោយសារមានការខឹងដាក់គ្នា។ ខ្លួនមិនស្គាល់អ្នកដែលគេគប់ត្រូវនោះទេ។ ខ្លួនគ្រាន់តែឈរនៅក្បែរគេទេ មិនបាន កាន់ដុំថ្មគប់គេនោះទេ ដោយសារខ្លួនមិនហ៊ានគប់។ ខ្លួនមិនដឹងថា គេគប់នោះត្រូវមនុស្សឬអត់នោះទេ តែឈ្មោះ ភាក់ ប្រាប់ថាគប់ត្រូវ។ ក្រោយកើតហេតុពីរថ្ងៃក្រោយ ទើបមានសមត្ថកិច្ចគេមកចាប់ខ្លួននៅផ្ទះ។ នៅថ្ងៃកើតហេតុ ខ្លួនបានទៅវត្តម្នាក់ឯង តែពេលទៅដល់វត្ត ឃើញគ្នាទើបហៅជុំគ្នា ហើយបានឈរនៅមុខក្លោងទ្វារវត្ត ហើយភាគី ខាងជនរងគ្រោះមានគ្នាបួននាក់ ដោយបានខឹងដាក់ខាងខ្លួនមុន តែមិនបានគប់នៅមុខវត្តនោះទេ ដោយសារមនុស្សច្រើន។ ឈ្មោះ ភាក់ ជាអ្នកបបួលស្ទាក់គប់។ ខ្លួនបីនាក់បានកាន់ដុំថ្ម។ ឈ្មោះ ភាក់ ជាអ្នកគប់មុន ហើយឈ្មោះ ម៉ៅ ជាអ្នកគប់បន្ទាប់ ហើយខ្លួនបានរើសដុំថ្ម តែមិនបានគប់ទេ។ ការគប់នោះគ្រាន់តែចង់ឱ្យគេរបួសទេ មិនមែនចង់ សម្លាប់នោះទេ។ ពេលពួនស្ទាក់ ខ្លួនបានកាន់ដុំថ្មត្រៀមគប់ហើយ ដោយឱ្យគេជិះហួសបន្តិច ហើយគប់ពីក្រោយ។ ខ្លួនចង់គប់គេដែរ តែដោយសារគេជិះហួស ទើបមិនបានគប់។ ចម្ងាយដែលគប់ គឺប្រហែល១៥ម៉ែត្រ។ សព្វថ្ងៃ ខ្លួនធ្វើការនៅខេត្តកំពង់សោម។ ខ្លួនសុំរក្សាចម្លើយមុនៗនៅដដែល។

- ជនជាប់ចោទឈ្មោះ [redacted] ម៉ៅ បានឆ្លើយបញ្ជាក់ថា៖ ខ្លួនបានកាន់ដុំថ្មមួយដុំ ហើយបានគប់ដែរ តែគប់ខុស។ តែឈ្មោះ ភាក់ ជាអ្នកគប់ត្រូវ តែខ្លួនគប់ខុស។ ឈ្មោះ [redacted] ចាន់ថន កាន់ដុំថ្មដែរ តែមិនបានគប់ទេ។ អ្នកគប់ដុំថ្មមានតែពីរនាក់ទេ។ ខាងជនរងគ្រោះ គឺមានគ្នាបួននាក់ ពីរម៉ូតូ តែគប់ត្រូវតែម្នាក់ទេ។ ក្រោយកើតហេតុពីរថ្ងៃមក ទើបខាងប៉ូលីសមកចាប់ខ្លួន។ ឈ្មោះ ភាក់ ជាអ្នកបបួលគប់ ហើយជាអ្នកគប់មុនគេ ទើបខ្លួនគប់បន្ទាប់។ ខ្លួនកាន់អំបែងក្បឿង មិនមែនដុំថ្មទេ។ ឈ្មោះ ភាក់ ប្រាប់ថា ឱ្យទៅវ៉ៃគេ ហើយគាត់នាំខ្លួនទៅ។ ខ្លួនទទួលស្គាល់ថា ខ្លួនបានប្រព្រឹត្តមែន។ ខ្លួនមិនបានបបួលឈ្មោះ ថន ទៅមើលល្ខោនទេ តែវាហៅខ្លួនទៅ។ ខ្លួនមិនមានលុយសងជនរងគ្រោះនោះទេ។ ខ្លួនគប់មិនបានសំដៅទៅអ្នកណាមួយនោះទេ ត្រូវមួយណាក៏បានដែរ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឡេក បានឆ្លើយបញ្ជាក់ថា៖ គេគប់ដុំថ្មត្រូវកូនខ្លួនចំភ្នែកខាងឆ្វេង ត្រូវរបួសភ្នែកខ្លាំង។ សព្វថ្ងៃ ភ្នែកកូនរបស់ខ្លួនមិនទាន់មើលឃើញ ប្រហែលជាអាចខ្វាក់ម្ខាង តែពេទ្យមិនទាន់ សន្និដ្ឋានថា មិនអាចមើលឃើញនោះទេ។ ខ្លួនមិនបានឃើញហេតុការណ៍នោះទេ ដោយគ្រាន់តែលឺតាមកូនប្រាប់។ នៅថ្ងៃកើតហេតុ កូនខ្លួនបានទៅមើលល្ខោន។ កូនខ្លួនមិនស្គាល់ជនជាប់ចោទទាំងពីរនាក់នេះទេ។ កូនខ្លួនមិនបាន មកចូលរួមសវនាការនេះទេ ដោយសារនៅដេកពេទ្យ មិនទាន់ជាសះស្បើយឡើយ។ ខ្លួនសុំទាមទារសំណងចំនួន ២០(ម្ភៃ)លានរៀល។ ខ្លួនមិនដឹងមូលហេតុអីដែលគេគប់កូនខ្លួននោះទេ។

- ក្រឡាបញ្ជីអានកំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់សាក្សីឈ្មោះ [redacted] សារី ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ធំ បានឆ្លើយបញ្ជាក់ថា៖ ខ្លួនត្រូវជាម្តាយបង្កើតរបស់ ឈ្មោះ [redacted] ចាន់ថន ភេទប្រុស កើតឆ្នាំ២០០៧។ សព្វថ្ងៃ ខ្លួនពុំមានមុខរបរចិញ្ចឹមជីវិតទេ ខ្លួនមានជីវភាពក្រីក្រ ណាស់ (មានបណ្ណក្រីក្រ) មានតែកូនប្រុសរបស់ខ្លួន ជាអ្នកដើរស៊ីឈ្នួលរកលុយចិញ្ចឹមគ្រួសារទេ។ នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង៨យប់ ខ្លួន និងកូនឈ្មោះ [redacted] ចាន់ថន បាននាំគ្នាទៅមើល ល្ខោននៅវត្ត រលាប នៅពេលកំពុងមើលល្ខោន កូនរបស់ខ្លួនឈ្មោះ [redacted] ចាន់ថន បានសុំទៅលេងនៅលើវិហារបាត់ទៅ។ បន្ទាប់ពីមើលល្ខោនចប់ ខ្លួនក៏បានមកផ្ទះវិញ នៅម៉ោង១១យប់ រីឯ កូនរបស់ខ្លួន មិនដឹងថាមកដល់ផ្ទះនៅពេល ណាទេ។ នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៣ សមត្ថកិច្ចបានចុះមកឃាត់ខ្លួនកូនខ្លួន នៅផ្ទះរបស់ខ្លួននៅភូមិចារ ឃុំ ក្រវ៉ា ស្រុកបារាយណ៍ ខេត្តកំពង់ធំ។ ក្រោយមក ខ្លួនទើបដឹងថាកូនរបស់ខ្លួនជាប់ពាក់ព័ន្ធនឹងបទល្មើស ហិង្សាដោយ ចេតនាមានស្ថានទម្ងន់ទោស (គប់ដុំថ្ម) នៅចំណុចវត្តរលាប ស្ថិតនៅភូមិរលាប ឃុំក្រវ៉ា ស្រុកបារាយណ៍ ខេត្តកំពង់ធំ



Scanned with CamScanner

កាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣។ ហើយខ្លួនក៏បានជួបជាមួយនឹងឪពុករបស់ជនរងគ្រោះឈ្មោះ [redacted] ឡេក ហើយខ្លួនបានចរចារអំពីសំណង ដោយខ្លួនមានលទ្ធភាពបង់សំណង ចំនួន ១លានរៀល ប៉ុន្តែឪពុករបស់ជនរងគ្រោះមិនព្រមទទួលទេ គាត់ទាមទារសំណងចំនួន ៤,000ដុល្លារអាមេរិក។ ខ្លួនពុំមានលទ្ធភាពបង់សំណងឱ្យទៅជនរងគ្រោះនោះទេ។ ចំពោះសំណងដែលដើមបណ្ដឹងរដ្ឋប្បវេណីទាមទារ ខ្លួនទុកឱ្យតុលាការអនុវត្តតាមច្បាប់ចុះ។

- ក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ការបំភ្លឺឈ្មោះ [redacted] ឧត្តម ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៣ របស់អធិការដ្ឋាននគរបាលស្រុកបារាយណ៍ បានឆ្លើយបញ្ជាក់ថា៖ កាលពីយប់ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ រូបខ្លួនបានទៅលេងបុណ្យនៅវត្តព្រៃរលាប ដោយឈ្មោះ [redacted] ចាន់ថន ហៅ ក្រូច ជិះម៉ូតូជាមួយឈ្មោះ [redacted] ម៉ៅ ហៅ ត្រក មកយកខ្លួនដល់ផ្ទះ អង្គុយលេងប្រហែលម៉ោង២២:០០នាទី ពួកខ្លួនក៏មានទំនាស់ពាក្យសំដីគ្នាជាមួយក្រុមម្ខាងទៀតមានគ្នា០៥នាក់នោះ រួចក៏នាំគ្នាជិះម៉ូតូទៅផ្ទះ ស្រាប់តែឈ្មោះ [redacted] ចាន់ថន ហៅ ក្រូច និងឈ្មោះ [redacted] ម៉ៅ ហៅ ត្រក បានរើសដុំថ្មគប់ទៅលើពួកគេ ក៏ត្រូវចំឈ្មោះ [redacted] គីមហ៊ង ឃើញដូចនោះ ខ្លួនបានចេញសុំគេទៅផ្ទះមុន។

- ក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ការបំភ្លឺឈ្មោះ [redacted] សុខហ៊ាង ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៣ របស់អធិការដ្ឋាននគរបាលស្រុកបារាយណ៍ បានឆ្លើយបញ្ជាក់ថា៖ កាលពីយប់ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣ ពួកខ្លួនមានគ្នា០៥នាក់ បានជិះម៉ូតូទៅលេងបុណ្យនៅវត្តព្រៃរលាបបាននាំគ្នាអង្គុយនៅខឿនវិហារ មានមនុស្សមួយក្រុមមានគ្នា០៣ទៅ០៦នាក់បានដើរមកសំឡឹងពួកខ្លួន ឃើញដូចនោះ ពួកខ្លួនក៏នាំគ្នាដើរមកមើលល្ខោនវិញ។ ប្រហែលម៉ោង១០:៣០នាទី ពួកខ្លួនបានជិះទៅផ្ទះមកដល់ខាងលិចរបងវត្ត ស្រាប់តែមានមនុស្សមួយក្រុមនោះយកដុំថ្មគប់មកលើពួកខ្លួន ក៏ត្រូវចំភ្នែកឈ្មោះ [redacted] គីមហ៊ង ដួលម៉ូតូ។

**- ភស្តុតាងបានលើកយកមកសំអាងក្នុងសវនាការ៖**

១-កំណត់ហេតុស្រាវជ្រាវ និងពិនិត្យកន្លែងកើតហេតុ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៣ របស់អធិការដ្ឋាននគរបាលស្រុកបារាយណ៍។

២-កំណត់ត្រាស្លាកស្នាមរបួសឈ្មោះ [redacted] គីមហ៊ង របស់អធិការដ្ឋាននគរបាលស្រុកបារាយណ៍។

៣-សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតលេខ៖**៥៥៦៧** ចលបក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ របស់សាលាស្រុកបារាយណ៍ ដែលមានសំបុត្របញ្ជាក់កំណើតលេខ៖៣៧ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៨ របស់ឈ្មោះ [redacted] ចាន់ថន។

៤-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ៖**១៥១០២៤៩៥០** ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] ចាន់ថន។

៥-ប័ណ្ណសមធម៌លេខ៖**១២០៦០១១១០៤-០១៧២** ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] ចន្ថា។

៦-វេជ្ជបញ្ជា និងវិក័យប័ត្រ ចំនួន១១សន្លឹក។

**- វត្ថុចាប់យកបានលើកយកមកក្នុងសវនាការ៖** កំណត់ហេតុទទួលវត្ថុចាប់យកលេខ៖៩០/២០២៣ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ធំ ដែលមាន ដុំថ្មចំនួន០១ដុំ។

**- តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖** ឆ្លងកាត់ការពិភាក្សាដេញដោលនាពេលសវនាការ ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ ចម្លើយសាក្សី និងពិនិត្យភស្តុតាងនានា ឃើញថា ជនជាប់ចោទទាំងពីរនាក់ពិតជាបានរួមគ្នាប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់មែន ដូច្នេះ តំណាងអយ្យការប្តឹងសុំតម្កល់ការចោទប្រកាន់។

**- មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ធ្វើសេចក្តីសន្និដ្ឋានការពារ៖** ឆ្លងកាត់ការពិភាក្សាដេញដោលនាពេលសវនាការ ឃើញថា កូនក្តីខ្លួនគ្រាន់តែបានកាន់ដុំថ្ម តែមិនបានគប់ទៅលើ

ជនរងគ្រោះនោះទេ ដែលគ្រាន់តែជាអំពើនៃការប៉ុនប៉ងនោះទេ ប៉ុន្តែ ការប៉ុនប៉ងក្នុងបទល្មើសហិង្សា គឺមិនមានចែងនៅក្នុងច្បាប់នោះទេ។ម្យ៉ាងទៀត ជនជាប់ចោទទើបតែអាយុ១៦ឆ្នាំ ជាអនីតិជន មានកម្រិតសិក្សាខ្សោយ មានជីវភាពក្រីក្រ ដោយសារការសេពគប់ខុស។ ដូច្នេះ សូមតុលាការមេត្តាផ្តល់ស្ថានសម្រាលទោសដល់កូនក្តីខ្លួនផង។

**- សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់ថន និងឈ្មោះ [redacted] ម៉ៅ** សំណូមពរតុលាការបន្ធូរបន្ថយទោសឲ្យខ្លួនផង។

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ថ្ងៃទី..០៦..ខែ..៥.....ឆ្នាំ២០២៣ ក្រឡាបញ្ជី

[redacted]

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទទាំងពីរនាក់
- ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់ចម្លើយបណ្តាសាក្សី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានតំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីការពារជនជាប់ចោទ
- ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទទាំងពីរនាក់
- ក្រោយពីបានពិនិត្យភស្តុតាងនានាក្នុងសំណុំរឿង

## ៣.សំអាងហេតុ

**ក្រោយពីបានពិចារណាលើសេចក្តីសន្និដ្ឋានរបស់ភាគី ភស្តុតាង និងឯកសារនានាក្នុងសំណុំរឿង សាលាដំបូងខេត្តកំពង់ធំ៖**

១. **យល់ឃើញថា៖** តុលាការធ្វើការជំនុំជម្រះលើជនជាប់ចោទឈ្មោះ [redacted] ចាន់ថន ភេទប្រុស អាយុ១៦ឆ្នាំ កើតឆ្នាំ២០០៧ ជនជាប់ចោទឈ្មោះ [redacted] ម៉ៅ ភេទប្រុស កើតឆ្នាំ២០០៥ អាយុ១៨ឆ្នាំ និងជនជាប់ចោទឈ្មោះ [redacted] សុភាក់ ភេទប្រុស កើតឆ្នាំ១៩៩៥ (សាវតាជាតិខាងលើ) ដែលបានប្រព្រឹត្តអំពើដែលបណ្តាលឱ្យមានព្យសនកម្មកើតឡើង កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ នៅលើផ្លូវបេតុងខាងលិចរបងវត្តព្រៃណា ស្ថិតនៅភូមិរលាប ឃុំក្រវ៉ា ស្រុកបារាយណ៍ ខេត្តកំពង់ធំ ត្រូវបានជាប់ចោទពីបទ: **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារប្រើអាវុធ** តាមមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ។

**២. យល់ឃើញថា:** តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] **ចាន់ថន** និងជនជាប់ចោទឈ្មោះ [redacted] **ម៉ៅ** បានឆ្លើយបដិសេធប្រហាក់ប្រហែលគ្នាថា៖ ឈ្មោះ [redacted] ម៉ៅ បានកាន់ដុំថ្មមួយដុំ ហើយបានគប់ទៅលើជនរងគ្រោះ តែគប់ខុស រីឯ ឈ្មោះ [redacted] សុភាក់ ជាអ្នកគប់ត្រូវ ចំណែកឈ្មោះ [redacted] ចាន់ថន កាន់ដុំថ្មដែរ តែមិនបានគប់ទេ។ ផ្ទុយទៅវិញ តាមចម្លើយសាក្សីឈ្មោះ [redacted]ឧត្តម មានភាពស៊ីសង្វាក់ជាមួយភស្តុតាងនានា ដែលបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] ចាន់ថន ជនជាប់ចោទឈ្មោះ [redacted] ម៉ៅ និងជនជាប់ចោទឈ្មោះ [redacted] សុភាក់ ពិតជាបានរួមគ្នាធ្វើសកម្មភាពយកដុំថ្មគប់ទៅលើជនរងគ្រោះ បណ្តាលឱ្យរងរបួសភ្នែក ប្រព្រឹត្តនៅលើផ្លូវបេតុងខាងលិចរបងវត្តព្រៃណា ស្ថិតនៅភូមិរលាប ឃុំក្រវ៉ា ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ ប្រាកដមែន។ ដូច្នេះ គ្មានភស្តុតាងណាមួយដើម្បីអាចដោះបន្ទុកឲ្យជនជាប់ចោទបានឡើយ។

៣.**យល់ឃើញថា: តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ៖** តម្កល់ការចោទប្រកាន់ និងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមផ្លូវច្បាប់។ ចំពោះ សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ មានភាពជឿជាក់បានថា អំពើរបស់ជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ និងតុលាការយល់ស្របតាមការប្តឹងសុំនេះ។

៤.**យល់ឃើញថា:** ជនជាប់ចោទឈ្មោះ [redacted] **ចាន់ថន** និងជនជាប់ចោទឈ្មោះ [redacted] **ម៉ៅ** បាននិយាយសំដីចុងក្រោយ៖ សំណូមពរតុលាការបន្ធូរបន្ថយទោសឲ្យខ្លួនផង និង**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ**



Scanned with CamScanner

[redacted] ធ្វើសេចក្តីសន្និដ្ឋានការពារ៖ សូមឱ្យតុលាការមេត្តាផ្តល់ស្ថានសម្រាលទោសដល់កូនក្តីខ្លួនផង។ តុលាការធ្វើការពិចារណា និងសម្រេចតាមច្បាប់។

៥. យល់ឃើញថា៖ មានពិរុទ្ធភាព និងមានភស្តុតាងនានាគ្រប់គ្រាន់ បានធ្វើឱ្យតុលាការជឿជាក់បានថា **អង្គហេតុខាងលើនេះ ជនជាប់ចោទឈ្មោះ** [redacted] **ចាន់ថន ជនជាប់ចោទឈ្មោះ** [redacted] **ម៉ៅ និងជនជាប់ចោទឈ្មោះ** [redacted] **សុភាក់** ពិតជាបានរួមគ្នាធ្វើសកម្មភាពយកដុំថ្មគប់ទៅលើជនរងគ្រោះ បណ្តាលឱ្យរងរបួសស្នាម ដែលត្រូវជាប់ចោទពីបទៈ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារប្រើអាវុធ** ប្រព្រឹត្តនៅលើផ្លូវបេតុងខាងលិចវត្តព្រៃលា ស្ថិតនៅភូមិរលាប ឃុំក្រវ៉ា ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣ តាម **មាត្រា២១៨** នៃក្រមព្រហ្មទណ្ឌ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០(បួនលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល។

៦. យល់ឃើញថា៖ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **ចាន់ថន** ជនជាប់ចោទឈ្មោះ [redacted] **ម៉ៅ** និងជនជាប់ចោទឈ្មោះ [redacted] សុភាក់ ដែលធ្វើសកម្មភាពខាងលើ បានស្តែងចេញមកខាងក្រៅ ហើយក៏មានចេតនាក្នុងការប្រព្រឹត្ត ដោយអំពើនេះវាធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយសណ្តាប់ធ្នាប់សាធារណៈ និងខុសច្បាប់រដ្ឋជាធរមាន តុលាការសម្រេចពីការផ្តន្ទាទោសតាមគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌតាមមាត្រា៤ និង **មាត្រា៩៦** នៃក្រមព្រហ្មទណ្ឌ។

៧. យល់ឃើញថា៖ ដោយស្ថានភាពនៃអង្គហេតុ និងបានបញ្ចប់ការពិភាក្សាដេញដោលលើជនជាប់ចោទ បានបញ្ជាក់ថា កាលៈទេសៈនៃការប្រព្រឹត្ត បុគ្គលិកលក្ខណៈរបស់ជនជាប់ចោទឈ្មោះ [redacted] **ចាន់ថន ជាអនីតិជនមានអាយុចាប់ពី១៤ឆ្នាំឡើង** តុលាការសម្រេចពីការប្រកាសទោស តាមមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ។

៨. យល់ឃើញថា៖ ជនជាប់ចោទឈ្មោះ [redacted] **សុភាក់** គ្រប់ដំណាក់កាលនៃការស៊ើបអង្កេត ស៊ើបសួរ និងជំនុំជម្រះ តុលាការបានចាត់ការតាមនីតិវិធី **ដើម្បីរក្សាសិទ្ធិឱ្យជនជាប់ចោទក្នុងការបង្ហាញការពិត** និងតទល់ចំពោះការចោទប្រកាន់នានា ប៉ុន្តែ ជនជាប់ចោទនៅបន្តអវត្តមាន និងបានគេចវេសមិនបានចូលខ្លួនមកនៅគ្រប់ដំណាក់កាល។ ម្យ៉ាងវិញទៀត ដើម្បីធានារបៀបរៀបរយសណ្តាប់ធ្នាប់សាធារណៈក្នុងសង្គម និងអនុវត្តច្បាប់រដ្ឋជាធរមាន បទល្មើសដែលចោទប្រកាន់លើជនជាប់ចោទមានកម្រិត ១(មួយ)ឆ្នាំ តុលាការធ្វើការសម្រេចឱ្យចាប់ខ្លួន និងឃុំខ្លួនជនជាប់ចោទ តាម**មាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ**។

៩. យល់ឃើញថា៖ ជនជាប់ចោទមានពិរុទ្ធភាពក្នុងអំពើដែលបានប្រព្រឹត្ត ដូច្នេះ ជនជាប់ចោទត្រូវតែទទួលខុសត្រូវសំណងផ្នែករដ្ឋប្បវេណីចំពោះអំពើប្រព្រឹត្តរបស់ខ្លួន។ ដើមបណ្តឹងរដ្ឋប្បវេណីទាមទារសំណងប្រាក់ថ្លៃព្យាបាលចំនួន ២០(ម្ភៃលាន)រៀល ដែលជាការទាមទារនេះមានលក្ខណៈច្រើនហួសហេតុ គប្បី តុលាការពិចារណា និងសម្រេចអោយធួនល្មមទៅនឹងព្យសនកម្មដែលកើតឡើងជាក់ស្តែង និងទៅតាមកម្រិតជីវភាពរបស់ជនជាប់ចោទ។

១០.យល់ឃើញថា៖ វត្ថុដែលចាប់យក តាមកំណត់ហេតុទទួលវត្ថុចាប់យកលេខ៖៩០/២០២៣ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ធំ ដែលមាន ដុំថ្មចំនួន០១ដុំ។ តុលាការធ្វើសម្រេចពីការរឹបអូសវត្ថុតាងតាមច្បាប់។

## ៤.សេចក្តីសម្រេច

## តាមសំអាងហេតុ និងក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តកំពង់ធំសម្រេច ÷

១. ផ្តន្ទាទោសលើ៖

១.១. ឈ្មោះ [redacted] ចាន់ថន ភេទប្រុស អាយុ១៦ឆ្នាំ កើតឆ្នាំ២០០៧ (សាវតាជាតិខាងលើ) **ដាក់ពន្ធនាគារ** កំណត់ ២(ពីរ)ឆ្នាំ និង ៦(ប្រាំមួយ)ខែ



Scanned with CamScanner

១.២. ឈ្មោះ [redacted] ម៉ៅ ភេទប្រុស កើតឆ្នាំ២០០៥ អាយុ១៨ឆ្នាំ (សាវតាជាតិខាងលើ) ដាក់ពន្ធនាគារកំណត់ ៣(បី)ឆ្នាំ និង ៦(ប្រាំមួយ)ខែ

១.៣. ឈ្មោះ [redacted] សុភាក់ ភេទប្រុស កើតឆ្នាំ១៩៨៥ (សាវតាជាតិខាងលើ) ដាក់ពន្ធនាគារកំណត់ ៤(បួន)ឆ្នាំ

ជាប់ចោទពីបទ: **មនុស្សឃាតដោយចេតនាមានស្ថានទម្ងន់ទោសដោយសារប្រើអាវុធ** ប្រព្រឹត្តនៅលើផ្លូវប៉េតុងខាងលិចរបងវត្តព្រៃលា ស្ថិតនៅភូមិរលាប ឃុំក្រវ៉ា ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣ តាម**មាត្រា២១៨** នៃក្រមព្រហ្មទណ្ឌ។

២. **សំណងរដ្ឋប្បវេណី៖** បង្គាប់ឱ្យពិរុទ្ធជន

១.១. ឈ្មោះ [redacted] ចាន់ថន ភេទប្រុស អាយុ១៦ឆ្នាំ កើតឆ្នាំ២០០៧ (សាវតាជាតិខាងលើ)

១.២. ឈ្មោះ [redacted] ម៉ៅ ភេទប្រុស កើតឆ្នាំ២០០៥ អាយុ១៨ឆ្នាំ (សាវតាជាតិខាងលើ)

១.៣. ឈ្មោះ [redacted] សុភាក់ ភេទប្រុស កើតឆ្នាំ១៩៨៥ (សាវតាជាតិខាងលើ)

រួមគ្នាសងសំណងការខូចខាតជាសាមគ្គី **ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឡេក** ចំនួន ១៥.០០០.០០០ (ដប់ប្រាំលាន)រៀល ជាកំណត់ ការទាមទារលើសពីនេះត្រូវច្រានចោល។

៣. **បង្គាប់អោយចាប់ខ្លួន និងឃុំខ្លួនលើពិរុទ្ធជនឈ្មោះ [redacted]** សុភាក់ ភេទប្រុស កើតឆ្នាំ១៩៨៥ (សាវតាជាតិខាងលើ) យកមកអនុវត្តទោសពន្ធនាគារ និងបង្គាប់ឱ្យប្រធានពន្ធនាគារឃុំខ្លួន**ពិរុទ្ធជនេះ** ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ តាមមាត្រា **៣៥៣** នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤. **រឹបអូសវត្ថុតាង៖** ត្រូវរឹបអូស ចំពោះវត្ថុចាប់យក ដែលមាន ដុំថ្មចំនួន០១ដុំ តាមមាត្រា៦២ និងមាត្រា៦៣ នៃក្រមព្រហ្មទណ្ឌ។

សាលក្រមនេះបានធ្វើការជំនុំជម្រះនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣ និងបានប្រកាសជាសាធារណៈថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **ចាន់ថន** និងជនជាប់ចោទឈ្មោះ [redacted] **ម៉ៅ** កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] **សុភាក់** និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ឡេក**។

តុលាការបើកផ្លូវឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមច្បាប់កំណត់។

ថ្ងៃពុធ ៩រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ខេត្តកំពង់ធំ ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២៣

**ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted] [redacted] [redacted] [redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ២០២៣
ក្រឡាបញ្ជី

[redacted]



Scanned with CamScanner